ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥២៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០២

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់រង្វាន់ក្របខណ្ឌ (?) ការកែតម្រូវង្វាន់បុរេប្រទាន

## នៅក្រសួងអប់រំ យុវជន និង កីឡា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១/ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/ រកម /១២០១ /១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរង្វាន់ទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

ប្រការ១ : ត្រូវបានតែងតាំង ÷

-កញ្ញា ចាប សុភា ឋានៈអនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានហិរញ្ញវត្ថុ ជារដ្ឋលេខាធិការបុរេប្រទាន

-លោក សេង រ៉ីទុន ជារដ្ឋទេយ្យករបុរេប្រទានជំនួស ។

ប្រការ២:ការតែងតាំងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ៣:រាល់សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤:អគ្គលេខាធិការ.នាយកខុទ្ទកាល័យ.ប្រធានរតនាគារជាតិ.ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច.ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡា ព្រមទាំង កញ្ញា ចាប សុភា និង លោក សេង រ៉ីទុន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

តុល . ឡះ

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"

-ដូចប្រការ៣ "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ